## រឿងទី៣៖ ព្រះយេស៊ូស្រឡាញ់ក្មេងៗ

**ខគម្ពីរ៖ ម៉ាថាយ១៩:១៤**

នោះព្រះយេស៊ូទ្រង់មានព្រះបន្ទូលថា ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ
ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវាពល់គ្នា

ព្រះយេស៊ូបានយាងមកដល់ភូមិយូដាជាមួយពួកសិស្ស ដើម្បីផ្សាយដំណឹងល្អពីនគរព្រះជាម្ចាស់។
គ្រប់កន្លែងដែលព្រះយេស៊ូយាងទៅ តែងតែមានមនុស្សមកប្រមូលផ្តុំគ្នាយ៉ាងច្រើន។
ហើយក្នុងនោះ ក៏មានឪពុកម្តាយដែលបាននាំកូនៗមកជាមួយផងដែរ។
ក្មេងៗសប្បាយចិត្តខ្លាំងណាស់ ដោយព្រោះគិតថាបានជួបព្រះយេស៊ូ!
ពួកគេបានឃើញព្រះយេស៊ូ!
ក្មេងៗបានរត់យ៉ាងលឿន ដើម្បីចូលទៅជិតព្រះយេស៊ូ។
ប៉ុន្តែ នៅពេលដែលក្មេងៗព្យាយាមទៅរកព្រះយេស៊ូ ស្រាប់តែពួកសិស្សបានឃាត់ក្មេងៗនិងឪពុកម្តាយពួកគេ
ព្រះយេស៊ូបានទតឃើញទិដ្ឋភាពនោះ ទ្រង់ក៏បានបន្ទោសពួកសិស្សថា៖
-ទុកឱ្យក្មេងៗមកឯខ្ញុំចុះ! កុំឱ្យឃាត់វាឡើយ! នគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវាពល់គ្នាដែរ! ឱ ពួកសិស្សទាំងអស់គ្នាអើយ ខ្ញុំសូមប្រាប់អ្នករាល់គ្នាឱ្យដឹងច្បាស់ថា ចូរជឿលើនគរព្រះជាម្ចាស់ដូចជាក្មេងតូចនេះ! អ្នកណាមិនព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ដូចក្មេងតូចមួយទេ អ្នកនោះចូលក្នុងព្រះរាជ្យព្រះអង្គមិនបានឡើយ។-
ព្រះយេស៊ូបានលាព្រះហស្តទាំងពីរទទួលក្មេងៗ។ ព្រះយេស៊ូបានឱបក្មេងៗ ហើយបានដាក់ព្រះហស្តប្រទានពរដល់ពួកគេ។
គ្រប់ទីកន្លែងដែលព្រះយេស៊ូយាងទៅ ទ្រង់តែងតែផ្តល់ក្តីស្រឡាញ់ដល់ក្មេងៗ ទ្រង់មិនធុញទ្រាន់នឹងពួកគេឡើយ។



- ចូរសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ (ម៉ាថាយ១៩:១៤)

ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ



**សកម្មភាពទី១** សូមសរសេរតាមអក្សរ ហើយបិទក្រដាសពណ៌ក្រហមតាមគែមបេះដូង។

ពួកយើងគឺជា
មិត្តភក្តិ។



ព្រះយេស៊ូ

**សកម្មភាពទី២** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

